# ព្រះរាជក្រម

នស/រកម/០៩៩៩/១១

## យើង

## ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ
## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើជាផ្លូវការ នូវច្បាប់ធម្មនុញ្ញ ស្តីពី វិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី៨ ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦ នស ៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំពី សម្តេចនាយករដ្ឋមន្ត្រី និងអំពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសអោយប្រើ

ច្បាប់ស្តីពី ការធ្វើវិសោធនកម្មមាត្រា ៥១ នៃច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ១៧ ខែ សីហា ឆ្នាំ១៩៩៩ នាសម័យប្រជុំវិសាមញ្ញនីតិកាលទី២ នៃរដ្ឋសភា និងដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាម លើទំរង់ និងគតិនៃច្បាប់នេះទាំងស្រុង នៅថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩៩ នាសម័យប្រជុំវិសាមញ្ញ នីតិកាលទី១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

# ច្បាប់
# ស្តីពី
# ការធ្វើវិសោធនកម្មមាត្រា ៥១
# នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល

**មាត្រាតែមួយ.-**

មាត្រា ៥១ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ត្រូវធ្វើវិសោធនកម្ម ដូចតទៅ ៖

**មាត្រា ៥១ ថ្មី.-**

ក្នុងករណីដែលមន្ត្រីរាជការណាម្នាក់ប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ហើយត្រូវបានព្រះរាជអាជ្ញាសំរេចធ្វើការចោទប្រកាន់ ព្រះរាជអាជ្ញាត្រូវជូនដំណឹងអំពីការចោទប្រកាន់នោះ ទៅប្រធានស្ថាប័នសាមីក្នុងរយៈពេល ៧២ ម៉ោងយ៉ាងយូរ ។

បើមានការចាប់ខ្លួន ឬការឃាត់ខ្លួន ឬការឃុំខ្លួនជាបណ្តោះអាសន្នលើមន្ត្រីរាជការណាមួយនោះ ព្រះរាជអាជ្ញា ឬចៅក្រមមានសមត្ថកិច្ចត្រូវរាយការណ៍ជាបន្ទាន់ទៅប្រធានស្ថាប័នសាមី ។

ក្នុងករណីដែលបទល្មើសនោះកើតមានក្នុងក្របខ័ណ្ឌនៃការបំរើការងារសាធារណៈ រដ្ឋត្រូវការពារមន្ត្រីរាជការនោះ តាមផ្លូវច្បាប់ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ១៩៩៩

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

បានបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រីស្តីទី**

**ហត្ថលេខា**

**ស ខេង**

បានជំរាបជូន សម្តេចនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ហត្ថលេខា**

**អ៊ុក វិធុន**

លេខៈ ១៩៥ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៩

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ហត្ថលេខា និង ត្រា**

**ណាឌី តាន់**